**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**<u>នាយកដ្ឋានព័ត៌មាន</u>**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃដំណើរទស្សនកិច្ច និងការអញ្ជើញចូលរួម កិច្ចប្រជុំកំពូល ពិភពលោកឆ្នាំ ២០២០ ក្រោមប្រធានបទ «សន្តិភាព សន្តិសុខ និងការអភិវឌ្ឍមនុស្ស» របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋកូរ៉េ ពីថ្ងៃទី ០៣ ដល់ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២០

-------

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ដោយជោគជ័យនូវដំណើរបំពេញទស្សនកិច្ច និងការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០២០ រៀបចំដោយសហព័ន្ធសន្តិភាពសាកល ក្រោមប្រធានបទ **«សន្តិភាព សន្តិសុខ និងការអភិវឌ្ឍមនុស្ស»** នៅ សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី០៣ ដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០ ។

ក្នុងអំឡុងទស្សនកិច្ចនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយ**ឯកឧត្តម មូន ចេអ៊ីន** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ និងផ្លាស់ប្តូរយោបល់ក្នុងឱកាសអាហារថ្ងៃត្រង់ជាមួយ **ឯកឧត្តម ជុង សៃយ្យូន** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋកូរ៉េ ស្តីពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ។**សម្តេចតេជោ**ក៏បានទទួលជំនួបសម្តែងការគួរសមដោយឥស្សរជនពីររូប គឺ **ឯកឧត្តម បាន គីមូន** អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ បច្ចុប្បន្នជាប្រធានវិទ្យាស្ថានកំណើនបៃតង និងជាប្រធានក្រុមប្រឹក្សាជាតិកូរ៉េស្តីពីអាកាសធាតុ និងគុណភាពខ្យល់ និង **សាស្ត្រាចារ្យ អាន មូនស៊ុក** សហប្រធានគណៈកម្មាធិការជម្រុញរដ្ឋាភិបាលអេឡិកត្រូនិក (e-Government) នៃសាធារណរដ្ឋកូរ៉េ ហើយនិងបានជួបណេះសំណាលជាមួយប្រជាជនខ្មែរ ប្រមាណ ជាង១០០០នាក់ ដែលកំពុងស្នាក់នៅ ធ្វើការ និងសិក្សាក្នុងសាធារណរដ្ឋកូរ៉េ ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **ឯកឧត្តមប្រធានាធិបតី មូន ចេអ៊ីន** បានសម្តែងការពេញចិត្តចំពោះភាពរឹងមាំនៃចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌទ្វេភាគីនិងពហុភាគី រវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ ដោយបានរំលឹកអំពីលទ្ធផលប្រកបដោយផ្លែផ្កានៃទស្សនកិច្ចរបស់ឯកឧត្តម **មូន ចេអ៊ីន** នៅកម្ពុជា កាលពីខែមីនា ឆ្នាំ២០១៩ និងសារសំខាន់នៃកិច្ចព្រមព្រៀងទ្វេភាគីដែលបានចុះហត្ថលេខាក្នុងឱកាសទស្សនកិច្ចនេះ និងក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ាន-សាធារណរដ្ឋកូរ៉េ



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

និងមេគង្គ-សាធារណរដ្ឋកូរ៉េ នៅក្រុងប៊ូសាន កាលពីខែវិច្ឆិកា ឆ្នាំ២០១៩ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ជនបទ វិនិយោគ ពាណិជ្ជកម្ម កសិកម្ម សុខាភិបាល បច្ចេកវិទ្យាព័ត៌មាន ហិរញ្ញវត្ថុ និងការអនុវត្តច្បាប់។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** និង ឯកឧត្តម**ប្រធានាធិបតី មូន ចេអ៊ីន** ឯកភាពជម្រុញការចរចាដើម្បីឈានទៅរកការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-សាធារណរដ្ឋកូរ៉េ ឲ្យបានក្នុងពេលឆាប់ៗ ដើម្បីពង្រីកពាណិជ្ជកម្មទ្វេភាគី ដែលពីឆ្នាំ២០១៩ បានកើនដល់ជាង១ពាន់លានដុល្លាអាមេរិក ហើយនឹងលើកទឹកចិត្តឲ្យមន្ត្រីទាំងសងខាងពិនិត្យចុះហត្ថលេខាឲ្យបានឆាប់ លើអនុស្សារណៈយោគយល់គ្នាស្តីពីសហប្រតិបត្តិការទេសចរណ៍ជំនួសអនុស្សារណៈចាស់។ ឯកឧត្តម**ប្រធានាធិបតី មូន ចេអ៊ីន** បានសម្តែងការអបអរសាទរជាមួយ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះការចាប់ផ្តើមនាំផ្លែស្វាយស្រស់កម្ពុជាចូលទីផ្សារសា.កូរ៉េ។ តបនឹងសំណូមពររបស់សម្តេចតេជោ ឯកឧត្តម **មូន ចេអ៊ីន** បានបញ្ជាក់ផងដែរថា នឹងបង្កើនការយកចិត្តទុកដាក់ជម្រុញកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម ព្រៃឈើ និងការអភិវឌ្ឍន៍ជនបទនៅកម្ពុជាបន្ថែមទៀត និងសន្យាខិតខំជំរុញឱ្យវិនិយោគិន និងក្រុមហ៊ុន សា.កូរ៉េ មកបណ្តាក់ទុននៅកម្ពុជាឱ្យបានកាន់តែច្រើន និងចាប់យកឱកាសចូលរួមក្នុងវិស័យកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅកម្ពុជា។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** ថ្លែងអំណរគុណរដ្ឋាភិបាលសា.កូរ៉េ ដែលបានផ្តល់ជំនួយឥត-សំណង និងឥណទានសម្បទានដល់ការអភិវឌ្ឍកម្ពុជាលើវិស័យជាច្រើន រួមទាំងហេដ្ឋារចនាសម្ព័ន្ធ និងស្នើសា.កូរ៉េ ពិនិត្យលទ្ធភាពសង់ស្ពានកាត់ទន្លេមេគង្គដើម្បីនិមិត្តរូបនៃមិត្តភាពប្រទេសទាំងពីរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានស្នើសុំអាជ្ញាធរសា.កូរ៉េ បន្តបង្កើនការទទួលយកពលករកម្ពុជា និងយកចិត្តទុកដាក់ចំពោះសុខមាលភាពរបស់ពួកគេ ក៏ដូចជាប្រជានកម្ពុជាដែលកំពុងស្នាក់នៅសា.កូរ៉េ ។

ស្តីពីកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ **ឯកឧត្តមប្រធានាធិបតី មូន ចេអ៊ីន** បានអរគុណចំពោះការខិតខំ និងការផ្តួចផ្តើមរបស់**សម្តេចតេជោ** ដែលបានធ្វើឲ្យកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-សាធារណរដ្ឋកូរ៉េ និងកិច្ចប្រជុំកំពូលមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១ ប្រព្រឹត្តទៅដោយជោគជ័យ នៅសា.កូរ៉េ កាលពីខែវិច្ឆិកា ឆ្នាំ២០១៩។ ឯកឧត្តម**ឯកឧត្តម មូន ចេអ៊ីន** ក៏បានអរគុណដល់រាជរដ្ឋាភិបាលកម្ពុជាដែលគាំទ្រគោលនយោបាយរបស់រដ្ឋាភិបាលសា.កូរ៉េ ដើម្បីកសាងសន្តិភាព និងវិបុលភាពរួមនៅឧបទ្វីបកូរ៉េ។ ជាមួយគ្នានេះ **ឯកឧត្តមមូន ចេអ៊ីន** បានសន្យានឹងអញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ នៅភ្នំពេញ ក្នុងខែវិច្ឆិកា ឆ្នាំ២០២០ ហើយបានបញ្ជាក់ថា នឹងផ្តល់ការគាំទ្រយ៉ាងសកម្មចំពោះកម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ។ ចំណែក **សម្តេចតេជោនាយករដ្ឋមន្ត្រីវិញ** បានឆ្លើយតបជាវិជ្ជមានចំពោះសំណើរបស់ **ឯកឧត្តម មូន ចេអ៊ីន** សុំអញ្ជើញតំណាងជាន់ខ្ពស់កម្ពុជា ចូលរួមក្នុង**កិច្ចប្រជុំកំពូលលើកទី២ ស្តីពីភាពជាដៃគូដើម្បីកំណើនបៃតង និងគោលដៅពិភពលោក២០៣០** ( 2nd P4G Summit: Partnership for Green Growth and the Global Goals 2030 ) នៅខែមិថុនា ឆ្នាំ២០២០ នៅទីក្រុងសេអ៊ូល។

ក្នុងជំនួបជាមួយ **ឯកឧត្តម បាន គីមូន សម្តេចតេជោ** បានបញ្ជាក់ថា នឹងពិនិត្យលទ្ធភាពទៅចូលរួមដោយផ្ទាល់ក្នុងកិច្ចប្រជុំកំពូល P4G លើកទី២ នៅថ្ងៃទី ២៨-២៩ មិថុនា ឆ្នាំ២០២០ និងបានផ្លាស់ប្តូរយោបល់យ៉ាងស៊ីជម្រៅពីបញ្ហាបម្រែបម្រួលអាកាសធាតុ និងការរួមចំណែករបស់កម្ពុជានៅក្នុង

ប្រតិបត្តិការថែរក្សាសន្តិភាពអង្គការសហប្រជាជាតិ។ ចំពោះកិច្ចពិភាក្សាជាមួយ **លោកសាស្ត្រាចារ្យ អាន មូនស៊ុក** បានផ្តោតទៅលើការជម្រុញកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងសា.កូរ៉េ លើការអភិវឌ្ឍន៍រដ្ឋាភិបាលអេឡិកត្រូនិក (e-Government) និងការបណ្តុះបណ្តាលធនធានមនុស្សកម្ពុជាលើផ្នែកនេះ ឲ្យសមស្របទៅនឹងស្ថានភាព និងតម្រូវការរបស់កម្ពុជា។

ដោយឡែក មុនពិធីបើកកិច្ចប្រជុំកំពូលពិភពលោកឆ្នាំ២០២០រៀបចំដោយសហព័ន្ធសន្តិភាពសាកល (UPF) **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានទទួល **លោកស្រី ហាក់ ចាហានមូន** ស្ថាបនិក UPF ចូលជួបសម្តែងការគួរសម ដោយបានផ្លាស់ប្តូរយោបល់គ្នាលើប្រធានបទសន្តិភាព សន្តិសុខ និងការអភិវឌ្ឍមនុស្ស បម្រែបម្រួលអាកាសធាតុ និងការវិវត្តន៍ថ្មីៗនៃការផ្ទុះឡើងនូវជំងឺផ្លូវដង្ហើមប្រភេទថ្មីបណ្តាលមកពីវីរុសកូរ៉ូណា ដែលជាកង្វល់របស់ពិភពលោក។

ក្នុងសន្ទរកថាគន្លឹះ លើប្រធានបទ «**សន្តិភាព សន្តិសុខ និងការអភិវឌ្ឍមនុស្ស**» នាឱកាសកិច្ចប្រជុំកំពូលខាងលើនេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអំពាវនាវឲ្យគ្រប់មជ្ឈដ្ឋាន ទាំងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល ខិតខំសកម្មចូលរួមចំណែករកវិធីដោះស្រាយបញ្ហាប្រឈមរួមជាសកល សំដៅរក្សា និងកសាងសន្តិភាព សន្តិសុខ និងចីរភាពនៃការអភិវឌ្ឍន៍សម្រាប់មនុស្សជាតិ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានលើកផងដែរថា កម្ពុជាដែលធ្លាប់ឆ្លងកាត់សង្គ្រាម និងវិបត្តិវិនាសកម្មដ៏ធំធេង បានផ្តល់តម្លៃខ្ពស់បំផុតដល់សន្តិភាព និងស្ថិរភាព ដែលបានផ្តល់ជាផ្លែផ្កាដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងវិបុលភាពសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានយល់ច្បាស់ថា ការបន្តរក្សាសន្តិភាព គឺមិនអាចកាត់ផ្តាច់បានពីការផ្តល់ឱកាសស្មើគ្នាជូនប្រជាជនគ្រប់រូបនូវផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាអភិវឌ្ឍធនធានមនុស្សឱ្យក្លាយទៅជាធនធាន ដែលមានសក្តានុពលមិនចេះរីងស្ងួត៕

ថ្ងៃ សុក្រ ១៤កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០